ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ២៩៩ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ០៣ ឆ្នាំ ២០០៩

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារបច្ចេកទេស
## សម្រាប់សិក្សាពីគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- យោងចំណាររបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ លើលិខិតលេខ ៥៩៣៥ សហវ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងលិខិតរបស់ក្រសួងពាណិជ្ជកម្មលេខ ០៥៧០ ព.ណបល ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៩
- យោងលិខិតរបស់ធនាគារជាតិនៃកម្ពុជាលេខធ៨.០៩.០០៦ចបជ ចុះថ្ងៃទី ១០ មករា ឆ្នាំ ២០០៩
- យោងលិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលេខ ១៥០/០៩ ករអក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៩

# សម្រេច

**ប្រការ ១.-** បង្កើត «ក្រុមការងារបច្ចេកទេសសម្រាប់សិក្សាពីគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា» ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១. | ឯកឧត្តមបណ្ឌិត **ម៉ិញ បានកុសល** | អគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា | ប្រធាន |
| ២. | ឯកឧត្តម **កៅ ថាច** | អគ្គនាយករង នៃគណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ៣. | ឯកឧត្តម **ខាវ ធុន្នី** | អគ្គលេខាធិការរងនៃគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤. | លោក **ទ៉ា សូទី** | ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រនិងទំនាក់ទំនងអន្តរជាតិ នៃគណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ៥. | លោក **សៀង ធីរិទ្ធ** | ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត នៃគណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ៦. | លោក **ឱម ដារារិទ្ធ** | ប្រធាននាយកដ្ឋាននីតិកម្ម នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧. | លោក **តាន់ សុវិឌ្យា** | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨. | លោកស្រី **ម៉ែន សុបភា** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩. | លោក **សេង រតនា** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០. | លោក **ប្រាក់ សុសេរីវុធ** | ប្រធានការិយាល័យនៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១១. | លោក **ហុង តូម៉ា** | អនុប្រធានផ្នែកនៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១២. | លោក **ហុង សុហួរ** | ជំនួយការឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ១៣. | លោក **ឆឹង ចន្ថា** | ប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៤. | លោក **អ៊ិន មាត្រា** | ប្រធានការិយាល័យធានារ៉ាប់រង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ២.-** ក្រុមការងារបច្ចេកទេសនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម:

១. សិក្សាស្រាវជ្រាវពីគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធក្នុងវិស័យមូលបត្រ ពិសេសចំពោះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ និងវិនិយោគិនមូលបត្រ នៃបណ្តាប្រទេសនានាក្នុងតំបន់ និងក្នុងពិភពលោក ។

២. សិក្សាពីគោលនយោបាយពន្ធ រួមទាំងការលើកទឹកចិត្តផ្នែកពន្ធដល់វិស័យផ្សេងៗ ដែលកំពុងអនុវត្តនៅកម្ពុជា ។

៣. សិក្សា និងវិភាគពីផលប៉ះពាល់នៃគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធក្នុងវិស័យមូលបត្រ និងចំណូលថវិកាជាតិ ។

៤. សិក្សា និងវិភាគ ព្រមទាំងគិតគូរយ៉ាងណាអោយគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធជំរុញអោយក្រុមហ៊ុន- សហគ្រាសខ្នាតតូច និងមធ្យមអាចទទួលផលពីគោលនយោបាយនេះ និងឈានទៅរកការបោះផ្សាយលក់មូលបត្រជាសាធារណៈ ។

៥. សិក្សា និងស្រាវជ្រាវពីច្បាប់ បទប្បញ្ញត្តិ និងកត្តាផ្សេងៗ ដែលអាចនាំឱ្យរាំងស្ទះដល់ការអនុវត្តគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធ ដោយលើកសំណើសុំការណែនាំ និងសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសម្រាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៦. ធ្វើរបាយការណ៍ជាប្រចាំ អំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធក្នុងវិស័យមូលបត្រនេះ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសម្រាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៧. រៀបចំសេចក្តីព្រាង «គោលនយោបាយលើកទឹកចិត្តផ្នែកពន្ធដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា» ដើម្បីសុំការណែនាំ និងសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសម្រាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៨. អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសម្រាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៣.-** រាល់ការងារពាក់ព័ន្ធនឹងគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធនេះ ត្រូវឆ្លងការណែនាំរបស់ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ជាអនុប្រធានប្រចាំការរបស់គណៈកម្មាធិការ

សម្រាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុននឹងស្នើសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសម្រាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤.-** ប្រធានក្រុមការងារមានសិទ្ធិអញ្ជើញសមាជិកក្រុមការងារ ដើម្បីប្រជុំគ្រប់ពេលវេលាតាមការចាំបាច់ ។ សមាជិកក្រុមការងារត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។ ពេលប្រធានអវត្តមាន ក្រុមការងារអាចប្រជុំក្រោមការដឹកនាំរបស់តំណាងតាមការប្រគល់សិទ្ធិរបស់ប្រធាន ដើម្បីធានានិរន្តរភាពនៃក្រុមការងារ ។

**ប្រការ ៥.-** ប្រធានក្រុមការងារអាចបង្កើតក្រុមសិក្សាស្រាវជ្រាវ និងវិភាគ តាមវិស័យ ឬតាមផ្នែកផ្សេងទៀត ទៅតាមការចាំបាច់ ដើម្បីធានានូវប្រសិទ្ធភាពនៃការងារ ។

**ប្រការ ៦.-** នាយកដ្ឋានកិច្ចការគតិយុត្ត នៃគណៈកម្មការមូលបត្រកម្ពុជា មានតួនាទីជាលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេស ដើម្បីសម្របសម្រួលនូវរាល់កិច្ចការរដ្ឋបាលផ្សេងៗដែលពាក់ព័ន្ធនឹងដំណើរការរបស់ក្រុមការងារ ។ ក្រុមការងារអាចប្រើប្រាស់ថវិការបស់គណៈកម្មការមូលបត្រកម្ពុជា ដើម្បីរ៉ាប់រង ក្នុងការចំណាយចាំបាច់ផ្សេងៗជាយថាហេតុរបស់ក្រុមការងារ ។

**ប្រការ ៧.-** ក្រុមការងារបច្ចេកទេសមានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ។

**ប្រការ ៨.-** អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង គណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានគណៈកម្មាធិការសម្រាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចំលងជូន:</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ធនាគារជាតិនៃកម្ពុជា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៨ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ